

SUSTAINABLE RICE SUMMIT 2020

# សេចក្តីប្រកាសព័ត៌មាន ស្តីពីកិច្ចប្រជុំកំពូលស្រូវអង្ករប្រកបដោយនិរន្តរភាព ឆ្នាំ២០២០

បន្ទាប់ពីប្រមូលផលបានច្រើននៅក្នុងឆ្នាំ២០១៩ រដ្ឋាភិបាលកម្ពុជារំពឹងទុកថានឹងមានអតិរេកស្រូវ ចំនួនប្រាំមួយ (៦) លានតោន ដែលស្ថិតនៅចំណាត់ថ្នាក់កំពូលនៃការប្រើប្រាស់ក្នុងស្រុក និងតម្រូវការឧស្សាហកម្មក្នុងស្រុក ក៏ប៉ុន្តែការវិនិយោគកាន់តែច្រើន និងការតភ្ជាប់ក្នុងចំណោមតួអង្គខ្សែសង្វាក់តម្លៃ គឺត្រូវការជាចាំបាច់នៅក្នុងឧស្សាហកម្មស្រូវអង្ករក្នុងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃនេះ ដៃគូពាក់ព័ន្ធក្នុងភាពជាដៃគូនៅកម្ពុជា បានរៀបចំកិច្ចប្រជុំកំពូលស្រូវអង្ករប្រកបដោយនិរន្តរភាពជាលើកដំបូង ដើម្បីដាក់ចេញនូវអត្ថប្រយោជ ន៍ដែលភាពជាដៃគូ រដ្ឋ-ឯកជន-ផលិតករ (Public-Private-Producer Partnerships - 4Ps) កំពុងប្រើប្រាស់គំរូអាជីវកម្មសហករ អាចនាំឆ្ពោះទៅកាន់ខ្សែសង្វាក់តម្លៃស្រូវអង្ករកម្ពុជា។ ព្រឹត្តិការណ៍នេះត្រូវបានចាប់ផ្តើមនៅរសៀលថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ តាមរយៈការសហការរៀបចំរួមគ្នា របស់សហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) ក្រុមហ៊ុនអេមរុ រ៉ាយស៍ និង ក្រុមហ៊ុនសាជីវកម្មកសិកម្មកម្ពុជា (ស៊ី.អេ.ស៊ី.ស៊ី)។ កិច្ចប្រជុំនេះ បានប្រមូលផ្តុំសហគមន៍កសិកម្មប្រមាណ៦០សហគមន៍ និងទីភ្នាក់ងារអភិវឌ្ឍន៍ដែលជាអ្នកសហការឧបត្ថម្ភថវិកាចំនួន១៤ស្ថាប័ន ដែលក្នុងនោះរួមមាន Australian Aid, កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា (CAVAC), Sweden Sverige-Oxfam កម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ និង ចម្រើន ក្រុមហ៊ុនអាហ្វ្រីប៊ីរឌី ក្រុមហ៊ុនបាយអូ-អាហ្គ្រូឆេម ក្រុមហ៊ុនត្រពិចខេម ក្រុមហ៊ុនកសិកម្មឡុងម៉េត ឯ.ក ក្រុមហ៊ុនបញ្ញីក្រុមហ៊ុន ៣៦៥ មូលរីង ឯ.ក ក្រុមហ៊ុនហុងហៀប និងអង្គការ Asia Recoerdo បណ្តាញកសិករ និងធម្មជាតិ។



ឧកញ៉ា ហ៊ុន ឡាក់ ប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា ជាអ្នកដឹកនាំព្រឹត្តិការណ៍នេះ។ លោកបានមានប្រសាសន៍ថា *"កិច្ចប្រជុំកំពូលស្រូវអង្ករប្រកបដោយនិរន្តរភាពនាថ្ងៃនេះ បាននាំមកនូវតួអង្គសំខាន់ទាំងបួនពីវិស័យសាធារណៈ វិស័យឯកជន ផលិតករ និងភាពជាដៃគូ ហើយសហករផលិតស្រូវប្រកបដោយនិរន្តរភាព ដោយជោគជ័យ ជាមួយនឹងទិន្នផលប្រសើរជាងមុន។* ***ជោគជ័យរបស់កសិករ គឺជាជោគជ័យរបស់សហគមន៍ស្រូវអង្ករទាំងមូល*** *"*។

ឯកឧត្តមបណ្ឌិត មី កល្យាណ ទីប្រឹក្សាជាន់ខ្ពស់ នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនសាជីវកម្មកសិកម្មកម្ពុជា (ស៊ី.អេ.ស៊ី.ស៊ី) បានមានប្រសាសន៍ថា "អាជីវកម្មដែលមានលក្ខណៈសហករណ៍អាចជួយពង្រឹងសេដ្ឋកិច្ចក្នុងស្រុក និងផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋខ្មែរ ជាពិសេសដល់ប្រជាជនដែលមិនសូវមានឱកាស ខណៈដែលពួកគេចាប់យកធនធានរបស់សហគមន៍។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពជាសកល (SDG) បញ្ជាក់ថាការអភិវឌ្ឍប្រកបដោយចីរភាព គឺជាស្នូលនៃសហគ្រាសសហករណ៍។ សហករណ៍ដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការឆ្លើយតបទៅនឹងតម្រូវការសហគមន៍មូលដ្ឋាន និងគោលបំណងនានា គំរូនៃអាជីវកម្មផ្អែកលើគោលការណ៍ និងគុណតម្លៃសីលធម៌ ដែលគោលដៅគឺដើម្បីផ្តល់នូវតម្រូវការ និងសេចក្តីប្រាថ្នារបស់សមាជិកខ្លួន "។



ឧកញ៉ា សុង សារ៉ន នាយកប្រតិបត្តិក្រុមហ៊ុនអេមរុ រ៉ាយស៍ (ខេមបូឌា) ឯ.ក និងជាប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានមានប្រសាសន៍ថា "ភាពជាដៃគូរបស់សហករកម្ពុជា ធនាគារជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយនិងក្រុមហ៊ុនធាតុចូលកសិកម្ម និងពាណិជ្ជករ កំពុងរីកចម្រើនឡើង។ វាកំពុងប្រចាប់បញ្ចូលខ្សែសង្វាក់តម្លៃស្រូវអង្ករ និងធ្វើឱ្យមានភាពស៊ីចង្វាក់គ្នាក្នុងចំណោមអ្នកពាក់ព័ន្ធផ្សេងៗ ឆ្ពោះទៅរកសន្ទុះកាន់តែខ្លាំងដល់ចលនាសហករណ៍ ដែលនឹងកសាងនូវសហគ្រិនភាព"។

"យើងមានមោទនភាពដែលបានរៀបចំព្រឹត្តិការណ៍លើកដំបូង ជាកិច្ចប្រជុំកំពូលស្រូវអង្ករប្រកបដោយនិរន្តរភាព។ វានឹងកំណត់បានមាគ៌ាត្រូវ ដែលភាគីពាក់ព័ន្ធនានានឹងផ្តោតលើ - ដោះស្រាយលើផលិតភាពរបស់កសិករខ្នាតតូច និងនិរន្តរភាពនៃខ្សែសង្វាក់តម្លៃ ដែលលើកកម្ពស់បរិយាកាសក្នុងភាពជាដៃគូដើម្បីនាំប្រជាជនចេញពីភាពក្រីក្រ អភិរក្សបរិស្ថាន និងការពារភពផែនដី។ វានឹងចូលរួមចំណែកក្នុងការកសាងសង្គម និងកសាងកិច្ចព្រមព្រៀងផ្អែកលើក្រម សីលធម៌ជាមួយវិស័យឯកជន ជាពិសេសជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដើម្បីគាំទ្រដល់ផលិតកម្មចំណាយទាប ផលិតផលសុវត្ថិភាពកាន់តែប្រសើរឡើង ការគោរពសិទ្ធិ និងប្រសិទ្ធផលក្នុងវិស័យស្រូវអង្ករ "។

ការច្នៃប្រឌិតបង្កើតថ្មីៗត្រូវបានចាប់ផ្តើម តាមរយៈភាពជាដៃគូនេះ នៅក្នុងខ្សែសង្វាក់តម្លៃស្រូវអង្ករប្រកបដោយនិរន្តរភាព។ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារដែលបានចូលរួម បានចាប់ផ្តើមសេវាកម្មហិរញ្ញវត្ថុដែលអាចជួយដល់សហករផលិតស្រូវ និងបានប្រមូលទិញពីសមាជិករបស់ខ្លួនវិញ ហើយដែលត្រូវបានធានាតាមរយៈគំរូកិច្ចសន្យាកសិកម្ម។ ការធ្វើពាណិជ្ជកម្មដោយសហករណ៍លើជីសរីរាង្គបានចាប់ផ្តើមកាលពីឆ្នាំមុន។ កម្មវិធីបច្ចេកវិទ្យា-ព័ត៌មាន ត្រូវបានអនុម័ត ដូចជា ប្រតិបត្តិការគ្មានសាច់ប្រាក់នៃ Block Rice ប្រព័ន្ធតាមដានផលិតផល និងព័ត៌មានទីផ្សារ ស្តីពីសន្ទស្សន៍តម្លៃច្បាស់លាស់។








